# មេរៀនទី៣
# តួនាទី
# អ្នកគ្រប់គ្រង
# នៅថ្នាក់ជាតិ
# និងក្រោមជាតិ



# សិទ្ធិរបស់ពលរដ្ឋ

# និង

# តួនាទីអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នក់ក្រោមជាតិ

# សិទ្ធិរបស់ពលរដ្ឋ

# សិទ្ធិរបស់ពលរដ្ឋ

"សិទ្ធិមនុស្ស គឺជាអ្វីៗដែល សំខាន់ចាំបាច់សម្រាប់ការរស់រានមានជីវិត ដែលប្រកប ដោយតម្លៃ និងសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស"។

នៅព្រះរាជាណាចក្រកម្ពុជា "សិទ្ធិមនុស្ស និងសេរីភាពបុគ្គល" ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញា ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

# ករណីកិច្ចរបស់ពលរដ្ឋ

- ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះប្រព្រឹត្តតាម លក្ខខណ្ឌ កំណត់ក្នុងច្បាប់ ។
- ប្រជាពលរដ្ឋខ្មែរ គ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។
- ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និង ការពារមាតុភូមិ ។
- ប្រជាពលរដ្ឋខ្មែរត្រូវគោរពគោលការណអធិបតេយ្យជាតិ និងលទ្ធិប្រជា ធិបតេយ្យសេរីពហុបក្ស ។

# យន្តការការពារសិទ្ធិមនុស្ស

- យន្តការការពារសិទ្ធិមនុស្សថ្នាក់អន្តរជាត
- យន្តការការពារសិទ្ធិមនុស្សថ្នាក់ជាតិ
- យន្តការការពារសិទ្ធិមនុស្សថ្នាក់មូលដ្ឋាន
- សមាគម-អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ
- ស្ថាប័នផ្សេងៗដែលផ្សព្វផ្សាយ ដោះស្រាយ និងជួយជនរងគ្រោះក្នុងករណីរំលោភសិទ្ធិមនុស្ស

# តួនាទី និង ភារកិច្ច

ការផ្តល់សិទ្ធិដល់សាធារណៈជនក្នុងការទទួលព័ត៌មាន និងតម្លាភាព។

ទៅមើលសាកសួរនិងស្វែងរកព័ត៌មានសាធារណៈ

ដាក់សំណើនិងសុំជំនួយអន្តរាគមនឬដោះស្រាយ បញ្ហាផ្សេងៗ

ចូលរួមក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ឬវេទិកាសាធារណនានា

ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា និងកិច្ចប្រជុំសាធារណៈនានារបស់ក្រុម ប្រឹក្សា

ផ្តល់ព័ត៌មានត្រឡប់ពីសហគមន៍

ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់និងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំ

សង្កាត់ចូលរួមក្នុងដំណើ រការកសាងផែនការរបស់ រដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ

ចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ

# តួនាទីអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នក់ក្រោមជាតិ

# សំណួរពិភាក្សា

1- តើអ្នកមានកាតព្វកិច្ចគ្រប់គ្រងជាអ្នកណា?

2- តើអ្នកមានកាតព្វកិច្ចគ្រប់គ្រងមានសិទ្ធិអ្វីខ្លះ?

3- តើអ្នកមានកាតព្វកិច្ចគ្រប់គ្រងមានតួនាទីភារកិច្ចអ្វីខ្លះ?

# ១. ផ្ទាក់ជាតិ

## ១.១. ស្ថាប័ននីតិប្រតិបត្តិ

### ១.១.១. ស្ថាប័នព្រះមហាក្សត្រ

ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជា និមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។

ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាលដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

## ១.១.២. ស្ថាប័រាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានភារកិច្ចកំណត់ និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ ដែលចែងក្នុងរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិ និងអង្គការតុលាការ ។
- រាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និង សកម្មភាពរបស់ខ្លួន ។

## ១.២. ស្ថាប័ននីតិបញ្ញត្តិ

### ១.២.១. រដ្ឋសភា

- រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចី ប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់ គេខ្ចី ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ
- រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាលអនុម័តច្បាប់ ស្តីពីការលើក លែងទោសជាទូទៅ ។
- អនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។
- រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម
- រដ្ឋសភា បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល

## ១.២.២. ព្រឹទ្ធសភា

- ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភានិងរដ្ឋាភិបាល ព្រឹទ្ធសភាពិនិត្យហើយអោយយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើក ដំបូងរួចហើយព្រមទាំងលើកបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។

  បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

  ក្នុងករណី ចាំបាច់ រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

## ១.២.៣. ក្រុមប្រឹក្សាធម្មនុញ្ញ

- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ
- បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបាន ពិនិត្យ ចប់សព្វគ្រប់ហើយ ។
- ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យនិងសំរេចអំពីករណីវិវាទកម្មទាក់ទង នឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

# ១.៣. អំណាចតុលាការ

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការធានារក្សា

អនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់

រួមទាំងរឿងក្តីរដ្ឋបាលផង ។ អំណាចនេះត្រូវប្រគល់អោយ

តុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

# រដ្ឋបាលថ្នាក់ក្រោមជាតិ

**រដ្ឋបាលថ្នាក់ក្រោមជាតិ**សំដៅលើ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និង រដ្ឋបាលឃុំសង្កាត់ ( អនុក្រឹត្យ ២១៦ មាត្រា ២) ។




ច្បាប់រៀបចំអង្គការ មាត្រា ១៨

# តើក្រុមប្រឹក្សារាជធានីក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សាក្រុងក្រុមប្រឹ ក្សាស្រុ កក្រុ មប្រឹ ក្សា ខណ្ឌ បង្កើតឡើងដោយរបៀបណា?

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតអសកលផ្ទាល់ពីក្រុមប្រឹក្សាឃុំសង្កាត់ ។



# ភាពខុសគ្នារវាងក្រុមប្រឹក្សា និងគណៈអភិបាល

| ក្រុមប្រឹក្សា | គណៈអភិបាល |
|---|---|
| បោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | តែងតាំងដោយរាជរដ្ឋាភិបាល |
| មានអាណត្តិ ៥ ឆ្នាំ | មានអាណត្តិ ៤ ឆ្នាំ |
| ធ្វើសេចក្ដីសំរេចសំរាប់ដែនដីរបស់ខ្លួន | អនុវត្តសេចក្ដីសំរេចដែលក្រុមប្រឹក្សាធ្វើ |
| មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និង រាជរដ្ឋាភិបាល | មានគណនេយ្យភាពចំពោះក្រុមប្រឹក្សា |
| ពិនិត្យមើលការងារគណៈអភិបាល | រាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ |
| អនុម័តផែនការ និង ថវិកាអភិវឌ្ឍន៍ | រៀបចំផែនការ និង ថវិកាអភិវឌ្ឍន៍ដើម្បីឱ្យក្រុមប្រឹក្សា ពិនិត្យ |
| អាចស្នើសុំដកហូត(ផ្លាស់ប្តូរ) អភិបាល/អភិបាលរង | អាចស្នើសុំដកហូតប្រធាន៖អនុប្រធានមន្ទីរនិងការិយាល័យជុំវិញ |

**ប្រភព:** ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៤.១៥.៣១.៣៤.៣៧.១៤៧.១៥២.១៥៥. និងអនុក្រឹត្យ២១៦ មាត្រា ១៣៥.១៤៥.១៤៦.១៤៧

១១

# ខ្សែគណនេយ្យភាព



# គណនេយ្យភាពចំពោះប្រជាពលរដ្ឋ



សំដៅទៅលើគណនេយ្យភាពរវាង រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ

ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលមានដូចជា:

- រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច ដើម្បីផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព ។
- រៀបចំឱ្យមានយន្តការសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការ ការរៀបចំ និងអនុវត្តផែនការ និងថវិកានិងសេចក្តីសម្រេចនានារបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ។
- រៀបចំឱ្យយន្តការសម្រាប់ការពារសិទ្ធិមនុស្សនិងផលប្រយោជន ប្រជាពលរដ្ឋនិងផ្តល់ព័ត៌មានដល់ប្រជាពល រដ្ឋឱ្យបានច្បាស់លាស់ទាន់ពេលវេលា និងទៀងទាត់ ។

# គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

- យកចិត្តទុកដាក់ជាពិសេសលើវត្តមានរបស់តួអង្គអភិវឌ្ឍន៍នានា ការសម្រេចចិត្តនិងការបង្កើតជម្រើសរួមគ្នា និងការអនុវត្តតួនាទីរបស់តួអង្គនានាជាពិសេសក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបសេចក្តី ត្រូវការរបស់ប្រជាពលរដ្ឋនិងបម្រើផលប្រ យោជន៍សាធារណៈដោយស្ថិតក្នុងក្របខ័ណ្ឌច្បាប់នានា។

- ជាមធ្យោបាយនានាដែលតម្រូវឱ្យក្រុមប្រឹក្សាដែលជាប់ឆ្នោតត្រូវស្តាប់នូវតម្រូវការរបស់ប្រជាពលរដ្ឋនិងសហគមន៍និងត្រូវបញ្ចូលនូវតម្រូវការទាំងនោះនៅក្នុងការពិភាក្សា និង ការសម្រេចរបស់ក្រុមប្រឹក្សា។

# គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

- កើតឡើងនៅពេលដែលប្រជាពលរដ្ឋអាចបង្ហាញកង្វល់ទាំងឡាយដល់តំណាងរបស់ពួកគេចំពោះជម្រើសអាទិភាពនានាការប្រើប្រាស់ធនធាននិងកម្រិតនៃការអនុវត្តការងាររបស់តំណាងទាំងអស់នោះ ។
- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជួបប្រជុំជាទៀងទាត់ជាមួយប្រជាពលរដ្ឋ និងក្រុមអ្នកទទួលផលនានា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីប្រមូលព័ត៌មាន និងពន្យល់បកស្រាយអំពីការសម្រេច របស់ខ្លួន ។

# ការពិគ្រោះយោបល់យ៉ាងល្អិតល្អន់

1. **ការសម្រេចចិត្តខាងនយោបាយ ត្រូវចែកដាច់ពីការងារបច្ចេកទេស**
   - ការសម្រេចចិត្តខាងនយោបាយរបស់ក្រុមប្រឹក្សា ត្រូវចែកដាច់ពីការងារបច្ចេកទេសរបស់គណអភិបាល
   - មាននិតិវិធី និងដំណើរការការងាររវាងតួអង្គនានាក្នុងរដ្ឋបាលក្រោមជាតិ
   - ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាផ្អែលើព័ត៌មានគណអភិបាល និងមន្ត្រីរបស់ក្រុមប្រឹក្ស

2. **ឱកាសនានាត្រូវបង្កើតសម្រាប់ធ្វើឲ្យការពិគ្រោះយោបល់កើតមាន**
   - បង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងលើកឡើងពីបញ្ហា
   - បង្កើតឱកាសសម្រាប់ក្រុមប្រឹក្សាក្នុងការលើកឡើងរបៀបវារៈពិភាក្សានានា
   - ឱកាសនយោបាយសម្រាប់ការពិភាក្សាលើបញ្ហានានា ការកំណត់អទិភាពសកម្មភាព និងការតាមដានវាយតម្លៃ








LA VIE EN ROSE



# តួនាទីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់និងគណនេយ្យភាពនៅមូលដ្ឋាន

## តួនាទីរបស់ក្រុមប្រឹក្សា

- រៀបចំប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឱ្យបានទៀតទាត់ ដោយមានការចូលរួមរបស់ប្រជាពលរដ្ឋ។ រៀបចំឱ្យមានប្រតិទិនប្រជុំ ច្បាស់លាស់ពេញមួយឆ្នាំ រួចផ្សព្វផ្សាយជាសាធារណៈអំពីប្រតិទិន របៀបវារៈ និងឯកសារសំខាន់ៗនានា។
- ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរាល់ដំណើរការរៀបចំផែនការ អភិវឌ្ឍន៍និងការធ្វើសេចក្ដីសម្រេចនានា។ វេទិកានិង វិធានការប្រមូលនិងផ្សព្វផ្សាយព័ត៌មាននានាត្រូវបង្កើតឡើងសម្រាប់ប្រជា ពលរដ្ឋ
- បង្កើតឱ្យមានគណៈកម្មាធិការនានាដើម្បីផ្ដល់យោបល់ដល់ក្រុមប្រឹក្សា



# តួនាទីរបស់ក្រុមប្រឹក្សា(ត)



- អនុញ្ញាត និងជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋអាចសុំ រឺពិនិត្យឯកសារសាធារណៈសំខាន់ៗរបស់ក្រុមប្រឹក្សា នៅការិយាល័យនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ផ្សព្វផ្សាយជាសាធារណៈនូវរាល់ព័ត៌មានសាធារណៈទាំងឡាយដូច ជារបាយការណ៍ សេចក្តីសម្រេចនានា ការអនុវត្តការងារ
- ចេញដីកានិងសេចក្តីសម្រេចនានាដើម្បីបំរើផលប្រយោជនដល់ ប្រជាពលរដ្ឋ
- បង្កើត និងពង្រឹងគណកម្មការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនិងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ
- អនុវត្តទួនាទី និងភារកិច្ចជាច្រើនផ្សេងទៀតដើម្បីបំរើប្រជាពលរដ្ឋ

# តួនាទីក្រុមប្រឹក្សា(ត)

- តំណាងសាធារណៈ គ្រប់គ្រង បម្រើផលប្រយោជន៍ប្រជាពលរដ្ឋ
- បង្កើតគោលនយោបាយ ធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយដើម្បីសម្រេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប៉ុន្តែមិនអនុវត្តសេចក្តីសម្រេច
- ត្រួតពិនិត្យការសម្រេចចិត្ត តួនាទី សកម្មភាពត្រូវបានអនុវត្ត
- *(ច្បាប់អង្គការមាត្រា 11,12,19,20,34 អនុក្រឹត្យ ពីតួនាទីនិងភារកិច្ច មាត្រា 6, 61,113)*

# អំណាចក្រុមប្រឹក្សា

- មានអំណាចប្រតិបត្តិដែលអាចប្រើក្នុងកិច្ចប្រជុំ តាមរយៈការធ្វើគោលនយោបាយ និងសេចក្តីសម្រេចនានា(OL—30 ,31, 33)
- មានអំណាចខាងបញ្ញាត្តក្នុងការ អនុម័ត វិសោធនកម្ម និងលប់ចោលឯកសារផ្លូវច្បាប់(OL—32 ,53, 61)
- អាចបង្កើតចំណូលតាមរយៈ (ពន្ធដា កម្រៃសេវាផ្សេង) ដោយផ្អែកលើច្បាប់(OL—២៩៦)
- មានអំណាចខាងគ្រប់គ្រងមន្ត្រី (ជួល កណត់ប្រាក់បៀរវត្ស បញ្ឈប់....)(OL—១៧៧)
- ក្រុមប្រឹក្សាអាចមានអំណាចផ្សេងទៀតតាមវិស័យក្នុងករណីមានការផ្ទេរតួនាទីភារកិច្ច (ការងារសហាគមននេសាទ ជាដើម....)
- ក្រុមប្រឹក្សាមានអំណាចដើម្បីធានាឲ្យគណអភិបាលមានគណនេយ្យភាព

# គណនេយ្យភាពរបស់ក្រុមប្រឹក្សា

ស្រដៀងគ្នាទៅនឹងរាជរដ្ឋាភិបាល ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះពលរដ្ឋនិងរដ្ឋ

- *គណនេយ្យភាពចំពោះប្រជាពលរដ្ឋ*
  - សម្រេចចិត្តបម្រើឲ្យផលប្រយោជន៍សធារណៈ(ច្បាប់អង្គការមាត្រា12,19)
  - យកចិត្តទុកដាក់គំនិតយោបល់របស់ពលរដ្ឋ*(ច្បាប់អង្គការមាត្រា12,36,38 និងអនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា9,14,63,70,115,132 និងផ្សេងៗទៀត*)
  - សម្រេចចិត្តដោយមានភស្តុតាងនិងព័ត៌មាន *(ច្បាប់អង្គការមាត្រា34 និងអនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា15,71,133)*
  - ធានាថាគណអភិបាលនិងមន្ត្រីនានាអនុវត្តការងារ ប្រើប្រាសធនធានអោយមានប្រសិទ្ធិភាព ប្រសិទ្ធផល ស្មោះត្រង់ ត្រឹមត្រូវតាមជម្រើសរីការសម្រេចរបស់ក្រុមប្រឹក្សា *(ច្បាប់អង្គការមាត្រា42,43,46,157,161,174,178 និងអនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា14,15,70,71,132,133)*

# គណនេយ្យភាពក្រុមប្រឹក្សាចំពោះរដ្ឋាភិបាល

- អនុវត្តតាមច្បាប់នានារបស់ប្រទេសក្នុងពេលក្រុមប្រឹក្សា
  - ធ្វើសេចក្តីសម្រេច
  - ការប្រកាស
  - ធ្វើវិសោធនកម្ម និងលប់ចោលសេចក្តីសម្រេចឬគោលនយោបាយ
  - បង្កើតចំណូល និងចំណាយធនធានដែលមានខ្លួនឯង
  - ធានាថាវិមជ្ឈការនិងមុខងារដែលផ្ទេរត្រូវបានអនុវត្ត *(ច្បាប់អង្គការមាត្រា13,24,35, 57,78ដល់88)*
- ក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះរដ្ឋក្នុងន័យកិច្ចការងារអនុវត្តច្បាប់ ប៉ុន្តែមិនមែនន័យនយោបាយ
- ក្រុមប្រឹក្សាមិនមានគណនេយ្យភាពចំពោះគណអភិបាលឬមន្ត្រីទេទេ។ ក្នុងករណីគណអភិបាលផ្តល់យោបល់អំពីការសម្រេចនិងសម្មភាពដែលជាទង្វើខុសច្បាប់ រដ្ឋាភិបាលនឹងចាត់វិធានការកែតម្រូវ។

# តួនាទីរបស់គណអភិបាលសំខាន់បី

1. ផ្តល់យោបល់ដល់ក្រុមប្រឹក្សា(តួនាទីបច្ចេកទេស)
2. គ្រប់គ្រងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា(តួនាទីគ្រប់គ្រង)
3. រាយការណ៍ពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា

- គណអភិបាលមានតួនាទីជាច្រើន**មុននិងក្រោយ**ការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- គណអភិបាលត្រូវទទួលយកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាមកអនុវត្តតាមទិសដៅដែលមានកំណត់

*(ច្បាប់អង្គការមាត្រា155ដល់170 និងអនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា 28,85,146 និងមាត្រាផ្សេងៗទៀត)*

# តួនាទីរបស់គណអភិបាលជួយក្រុមប្រឹក្សាអោយមានគណនេយ្យភាព

- ជួយក្រុមប្រឹក្សាឲ្យមានគណនេយ្យភាពដោយរាយការណ៍ជាទៀងទាត់
- ផ្តល់យុទ្ធសាស្រ្តពិគ្រោះយោបល់ជាមួយពលរដ្ឋ
- ផ្តល់ព័តមាននិងភស្តុតាងសម្រាប់ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេច
- ណែនាំពីភាពភាពត្រឹមត្រូវតាមច្បាប់និងបទដ្ឋានគតិយុត្តជាតិ
- ផ្តល់យោបល់លើបណ្តឹងនានា
- ធានាអោយការគ្រប់គ្រងមានតម្លាភាពចំពោះក្រុមប្រឹក្សានិងពលរដ្ឋ។

*(ច្បាប់អង្គការមាត្រា155,156, 159, 160,164, 165,169,170 និងអនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា17,28,29,73,85,86,135,146,147 )*

# តួនាទីគណៈអភិបាល

- មានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា និងចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តច្បាប់នានា ។
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្រុកទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ ។
- សិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានាដូចជាការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធាន ការដោះស្រាយសំណូមពរ និងបញ្ហាប្រឈមរបស់ឃុំសង្កាត់ ការកសាងផែន ការនិងការផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន

# តួនាទីគណៈអភិបាល

- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុកអំពីច្បាប់និងធានាឱ្យមានការអនុវត្តច្បាប់ព្រម ទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ ។
- សម្របសម្រួល តម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង និងស្ថាប័ន ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន ។
- រាយការណ៍ អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាង ក្រសួង ស្ថាប័ននានា
- អនុវត្តទួនាទី និងភារកិច្ចជាច្រើនផ្សេងទៀតដើម្បីបំរើប្រជពលរដ្ឋ

# ភារកិច្ចទាំងពីររបស់អភិបាល

1. គណៈអភិបាលទទួលខុសត្រូវចំពោះក្រុមប្រឹក្សា (*អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា 27,31,84,88,145,149)*
1. អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជា ឬក្រសួងមើលការខុសត្រូវសម្របសម្រួលនិងដឹកនាំផ្ទាល់តាមផ្នែកនីមួយៗមានតួនាទីបំរើនិងទទួលខុសត្រូវថ្នាក់ជាតិ
2. អ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជាសំរាប់កិច្ចការសន្តិសុខ បង្គាប់បញ្ជាសាធារណៈ និង  ច្បាប់ និងសិទ្ធិមនុស្ស មានតួនាទីបំរើរនិងទទួលខុសត្រូវថ្នាក់ជាតិ ។



# គណនេយ្យភាពរបស់គណអភិបាល

- គណអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា (
    - *អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា 27,31,84,88,145,149)*
- ក្រុមប្រឹក្សាអាចណែនាំគណអភិបាលពីរបៀបក្នុងការអនុវត្តសកម្មភាព និងសេចក្តីសម្រេចណាមួយ
    - *(ច្បាប់អង្គការមាត្រា 155,162 ,163,164 អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា15,71,133 អនុក្រឹត្យពីការធ្វើផែនការមាត្រា22)*
- គណអភិបាលត្រូវរាយការណ៍ពីការអនុវត្តសកម្មភាពការងារ អនុវត្តច្បាប់និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាយ៉ាងហោចណាស់មួយខែម្តង
    - *(ច្បាប់អង្គការមាត្រា 159,165 អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា 17,28,29,73,85,86,135,146,147)*

# គណនេយ្យភាពរបស់គណអភិបាល

- ក្រុមប្រឹក្សាអាចស្នើគណអភិបាលឲ្យ
  - ពិភាក្សាលើការអនុវត្តសេចក្តីសម្រេច
  - ធ្វើរបាយការណ៍ ផ្តល់ព័ត៌មានរឺពិភាក្សាបញ្ហាបន្ទាន់ឬពិសេសណាមួយបាន
  - ឆ្លើយសំណួរនានានិងផ្តល់ការពន្យល់នានា

  *(ច្បាប់អង្គការមាត្រា 157 អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា15,71,133)*

- ក្រុមប្រឹក្សាត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការរបស់គណអភិបាលដើម្បីធានាថាគណអភិបាលអនុវត្តតាមទិសដៅដែលបានកំណត់ដោយក្រុមប្រឹក្សា
  - *(ច្បាប់អង្គការមាត្រា 157 អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា 14,15,17,70,71,73,132,133,135)*

- *អនុវត្តដូចក្រុមប្រឹក្សា គណអភិបាលមានគណនេយ្យភាពចំពោះ*

*រាជរដ្ឋាភិបាល ក្នុងការអនុវត្តតួនាទីរបស់ខ្លួនអោយស្របតាមរដ្ឋធម្មនុញ ច្បាប់នានានិងបទដ្ឋានគតិយុត្តផ្សេងៗ*

*(អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា27,84,145)*

# គណនេយ្យភាពរបស់គណអភិបាល

- សេចក្តីសម្រេចឬការអនុវត្តសកម្មភាពណាមួយរបស់គណអភិបាលដែលមិនបានសម្រេចដោយក្រុមប្រឹក្សាជាមុននោះទេគឺចាត់ថាសេចក្តីសម្រេចឬការអនុវត្តសកម្មភាពណាមួយនោះគ្មានសុពលភាព។*(ច្បាប់អង្គការមាត្រា 158 អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា32,89,150)*

- ក្រុមប្រឹក្សាត្រូវដោះស្រាយរាល់ទង្វើមិនស្របច្បាប់ណាមួយរបស់គណអភិបាល *(អនុក្រឹត្យពីតួនាទីភារកិច្ចមាត្រា15,71,133)*

- គណអភិបាលគឺត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ប្រសិនបើគណអភិបាលរំលោភសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាដែលជាអ្នកធ្វើសេចក្តីសម្រេច។

# តើមានយន្តការចុងក្រោយណាសម្រាប់ធានាឲ្យមានគណនេយ្យភាពក្នុងករណីគណអភិបាលឬអភិបាលរងមិនអនុវត្តតួនាទីបានល្អប្រសើរ?

- ក្រុមប្រឹក្សាអាចស្នើក្រសួងមហាផ្ទៃឲ្យដកអភិបាលឬអភិបាលរងដោយផ្អែកលើហេតុផលច្បាស់លាស់ដែលមានចែងក្នុងច្បាប់អង្គការនិងរួមទាំងក្រមសីលធមវិជ្ជាជីវះ
- ក្រសួងមហាផ្ទៃត្រូវចាត់វិធានការស្រាវជ្រាវជាបន្ទាន់

*(ច្បាប់អង្គការមាត្រា 151,152)*

# គណនេយ្យភាពរបស់អភិបាល

- ពេលដើរតួជាអ្នកតំណាងរដ្ឋាភិបាល អភិបាលមានគណនេយ្យភាពចំពោះ រដ្ឋាភិបាលកម្ពុជា
- ក្នុងនាមជាអ្នកតំណាងរដ្ឋាភិបាលទោះជាយ៉ាងណាត្រូវតែរាយការណ៍ជាប្រចាំ ទៅក្រុមប្រឹក្សា
- ក្រុមប្រឹក្សាមានសិទ្ធិផ្តល់អនុសាសន៍ និងសេចក្តីណែនាំដល់អភិបាលដូចនេះតំរូវការថ្នាក់មូលដ្ឋាននិងឧបសគ្គកើតមានអាចដោះស្រាយបាន
- អភិបាលត្រូវតែទទួលយកនូវអនុសាសន៍របស់ក្រុមប្រឹក្សា និងសេចក្តីណែនាំបន្ទាប់មកត្រូវរាយការណ៍ត្រលប់ទៅក្រុមប្រឹក្សា
- ក្រុមប្រឹក្សាអាចសំនូមពរដល់អភិបាលដើម្បីរាយការណ៍នៅពេលប្រជុំក្រុមប្រឹក្សាប្រសិនបើអភិបាលដើរតួជាអ្នកតំណាងរដ្ឋាភិបាលមានផលប៉ះពាល់លើច្បាប់និងការមិនពេញចិត្តរបស់ប្រជាពលរដ្ឋ ។

# បុគ្គលិក/មន្ត្រី

- ជំនួយការផ្ទាល់ខ្លួនរបស់ក្រុមប្រឹក្សា និង ក្រុមប្រឹក្សាផ្នែកបច្ចេកទេស និង ការងាររដ្ឋបាល   ដូចជា
  - ✓ ការធ្វើផែនការការិយាល័យថ្នាក់ខេត្ត ដែលមានជាអនុសាសន៍ និង យល់ព្រមពីក្រុង ស្រុក ខណ្ឌ  និង ឃុំ  និង ផែនការអភិវឌ្ឍឃុំ ( យោងតាមប្រកាស ការិ.លេខ៤ )
  - ✓ បុគ្គលិកផ្នែក រដ្ឋបាល និង ហិរញ្ញវត្ថុក្រុង ជួយរៀបចំកិច្ចប្រជុំ  វេទិកាពិគ្រោះយោបល់ និង ឯកសារហិរញ្ញវត្ថុ ។ (ប្រកាសការិ.លេខ១៧ )
- បុគ្គលិកតាមផ្នែកនីមួយៗអនុវត្តច្រើនរបស់ក្រុមប្រឹក្សា រួមមានការបំពេញ

មុខងារតាមផ្នែកនាពេលអនាគត (ប្រកាស ការិ.លេខ ៧ ១៧ និង ២៤)

- បុគ្គលិកជាពិសេស នាយករដ្ឋបាល  ហាក់មានតួនាទីជួយដល់ អភិបាល ក្នុងការ ហ្វឹកហាត់ ដើរតួជាអ្នកតំណាង រដ្ឋាភិបាល (អនុក្រឹត្យ តួនាទី ៣៧ ៣៩ ៥៨ ) ( ៩៤ ៩៦ ១៥៥ ១៥៧)

# គណនេយ្យភាពរបស់មន្ត្រី

- បុគ្គលិកនីមួយៗ ត្រូវស្ថិតក្រោមការមើលថៃ និង ការគ្រប់គ្រងពីប្រធានផ្នែក
- ប្រធានផ្នែកត្រូវមានការទទួលខុសត្រូវចំពោះនាយករដ្ឋបាល
- នាយករដ្ឋបាលមានគណនេយ្យភាពចំពោះគណអភិបាល និងក្រុមប្រឹក្សា
- រំលឹកឡើងវិញថា វាជាការសម្រេចចិត្តរបស់ក្រុមប្រឹក្សា ក្នុងការដាក់វិន័យបញ្ឈប់បុគ្គលិក ។

# តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ |
|---|---|---|---|---|---|
| **កសាងផែនការ** : ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលប្រចាំឆ្នាំ។ | ✓ | ✓ | ✓ | ✓ | ✓ |
| **គ្រប់គ្រងហិរញ្ញវត្ថុ** : ក្រុមប្រឹក្សារៀបចំ និងអនុម័តគម្រោង ថវិកាប្រចាំឆ្នាំ និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។ | ✓ | ✓ | ✓ | ✓ | ✓ |
| **តាមដានត្រួតពិនិត្យ និងវាយតម្លៃ** : ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃ ជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយរាប់បញ្ចូល ទាំងផ្នែកនៃផែនការអភិវឌ្ឍន៍... | ✓ | ✓ | ✓ | ✓ | ✓ |
| **គ្រប់គ្រងបុគ្គលិក** : ក្រុមប្រឹក្សាត្រូវពិនិត្យ និងសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងផលប្រយោជន៍ផ្សេងទៀតរបស់បុគ្គលិក។ | ✓ | ✓ | ✓ | ✓ | ✓ |
| **រៀបចំរបាយការណ៍** : ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តមិនឱ្យលើសពី សែសិបប្រាំ(៤៥)ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ... | ✓ | ✓ | ✓ | ✓ | ✓ |
| **ផ្សព្វផ្សាយព័ត៌មាន** : ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលឱ្យ សាធារណជន ទទួលព័ត៌មានអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ទាំងអស់... | ✓ | ✓ | ✓ | ✓ | ✓ |
| **រាយការណ៍អំពីសកម្មភាពរំលោភអំណាច** : ក្នុងករណីដែល មានការរំលោភ អំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ច រាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ | ✓ | ✓ | ✓ | ✓ | ✓ |
| **ដោះស្រាយវិវាទ** : ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយ វិវាទនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន... | ✓ | ✓ | ✓ | ✓ | ✓ |

ផលិតដោយ

ឧបត្ថម្ភដោយ

# សិទ្ធិនិងករណីកិច្ចប្រជាពលរដ្ឋក្នុងការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចង្អុលបង្ហាញនូវមូលដ្ឋាន គ្រឹះក្នុង ការធានាឱ្យមានការពិគ្រោះយោបល់ជាមួ ប្រជាពលរដ្ឋ

- ការផ្តល់សិទ្ធិដល់សាធារណៈជនក្នុងការទទួលព័ត៌មាន និងតម្លាភាព។
- ទៅមើលសាកសួរនិងស្វែងរកព័ត៌មានសាធារណៈ
- ដាក់សំណើនិងសុំជំនួយអន្តរគមនឬដោះស្រាយ បញ្ហាផ្សេងៗ
- ចូលរួមក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាឬវេទិកាសាធារណៈនានា



# សិទ្ធិ និងករណីកិច្ចប្រជាពលរដ្ឋក្នុងការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ (ត)

- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សានិង កិច្ចប្រជុំសាធារណៈនានារបស់ក្រុមប្រឹក្សាផ្តល់ព័ត៌មានត្រឡប់ពីសហគមន៍
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់និងកម្មវិធីវិនិយោគប្រចាំឆ្នាំឃុំសង្កាត់ចូលរួមក្នុងដំណើ រការកសាងផែនការរបស់រដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ
- ចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ




ក្រុមប្រឹក្សាឃុំ សង្កាត់
មេឃុំ ចៅសង្កាត់
ជំទប់ទី១ ចៅសង្កាត់រងទី១
ជំទប់ទី២ ចៅសង្កាត់រងទី២
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
បុគ្គលិកឃុំ សង្កាត់
ស្មៀនឃុំ សង្កាត់
ភូមិ
ភូមិ
ភូមិ
ភូមិ
ភូមិ

# ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ទិសដៅវិមជ្ឈការនិងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គឺ ៈ

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋ ឱ្យចូលរួម កាន់តែទូលំទូលាយ នៅក្នុងការធ្វើ សេចក្តីសម្រេចចិត្ត ដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃជីវភាពរស់នៅ។

- ធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាជាមូលដ្ឋានផងដែរ ។
- ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពួកគាត់គិតថា អាចតំណាងឱ្យផលប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត
- ប្រជាពលរដ្ឋអាចបង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការងារដែល ពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ សង្កាត់

# ប្រជាពលរដ្ឋអាចចូលរួមតាមមធ្យោបាយជាច្រើន ដូចជា ៖

- ប្រជាពលរដ្ឋអាចលើកឡើងពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់នៅក្នុងកិច្ចប្រជុំរបស់ឃុំ
- ប្រជាពលរដ្ឋ អាចពិនិត្យតាមដានការអនុវត្តគម្រោងនៅក្នុងមូលដ្ឋានរបស់ខ្លួន
- ប្រជាពលរដ្ឋ មានសិទ្ធិចូលរួមទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយពួកគាត់អាចទៅកាន់សាលាឃុំ សង្កាត់ ដើម្បីទទួលព័ត៌មានផ្សេងៗ ដែលខ្លួនចង់ដឹង ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកប្រជាពលរដ្ឋមូលដ្ឋាន ហើយអាច ដឹងច្បាស់អំពីសេចក្តី ត្រូវការរបស់ប្រជាពលរដ្ឋ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំកម្មវិធី ដើម្បីកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុង មូលដ្ឋានរបស់ខ្លួន។

## ការធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាជាមូលដ្ឋានដូចជា៖

- ប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់យ៉ាងមាន ប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការ របស់ប្រជាពលរដ្ឋរបស់ខ្លួន
- ប្រជាពលរដ្ឋអាចពិនិត្យមើលការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ថាតើការប្រើប្រាស់ធនធានទាំងនេះពិតជាបម្រើឱ្យផលប្រយោជន៍ របស់ខ្លួនដែរឬទេ។

# តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

## តួនាទីបម្រើកិច្ចការមូលដ្ឋាន សម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន

ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច ៖

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើល ការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

## ១. ប្រធានក្រុមប្រឹក្សាឃុំសង្កាត់

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ធានាថាក្រុមប្រឹក្សាឃុំសង្កាត់បានប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែ
- ធានាថា កិច្ចប្រជុំត្រូវបានធ្វើឡើងស្របតាម បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

## ២. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- ធានាថា ក្រុមប្រឹក្សាឃុំសង្កាត់ប្រើប្រាស់អំណាច តួនាទី និងមុខងារ ដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋាន ពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

# ៣. មេឃុំ ចៅសង្កាត់

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការ អនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រម នៅពេលខ្លួនអវត្តមាន។

## ៤. ជំទប់ទី១ ចៅសង្កាត់រងទី១

- ទទួលជួយមេឃុំ ចៅសង្កាត់លើការងារហិរញ្ញវត្ថុ និងសេដ្ឋកិច្ច
- មេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី១ ចៅសង្កាត់រងទី១
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន។

# ៥. ជំទប់ទី២ ចៅសង្កាត់រងទី២

- ជួយមេឃុំចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសា ធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- មេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី២ ចៅ សង្កាត់រងទី២
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅ សង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន។

# ៦. គណៈកម្មាធិការនានា

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជា ការកសាងផែនការ និងថវិកា ។
- រាយការណ៍អំពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្ត ដែលពាក់ព័ន្ធទៅនឹងការងារ ។

# ៧. ស្មៀនឃុំ សង្កាត់

- ថ្វីត្បិតតែស្មៀនឃុំសង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាល របស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្ត ការងារ ស្មៀនឃុំសង្កាត់ត្រូវស្ថិត នៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នក ៖
- ជួយក្រុមប្រឹក្សា ក្នុងការបំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់

- បំពេញការងាររដ្ឋបាល
- ធានាថា សេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេច របស់ក្រុមប្រឹក្សាឃុំសង្កាត់ ស្របទៅនឹងល័ក្ខខ័ណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំ របស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានា របស់ឃុំសង្កាត់

- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឱ្យ អវត្តមានជាមុន ពីក្រុមប្រឹក្សាឃុំសង្កាត់ ឬមេឃុំ ចៅសង្កាត់។
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយ សេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និង មេឃុំ ចៅសង្កាត់ សម្រាប់ឱ្យសាធារណជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ។

## ៩. មេភូមិ និងជំនួយការមេភូមិ

ក). មេភូមិមានភារកិច្ច ដូចខាងក្រោម ៖

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុម ប្រឹក្សាឃុំ សង្កាត់
- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំសង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំសង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធ

- ត្រូវធ្វើសេចក្ដីរាយការណ៍រាល់បញ្ហា ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ របស់ ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំសង្កាត់
- ត្រូវធានាផ្ដល់ព័ត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ឯកសារ ព័ត៌មានអាចរួមមាន ព័ត៌មានស្ដីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំសង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន។

# សូមអរគុណ